# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបោះជំរុំកាយឫទ្ធិនៅភ្នំពេញថ្មី
# ថ្ងៃទី១៤ ឧសភា ២០១៧

អត្ថបទទី១៖ កក ៦,១-៧
អត្ថបទទី២៖ សល ២,៤-៩
ដំណឹងល្អ៖ យហ ១៤,១-១២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះនៅក្នុងកិច្ចគ្រិស្តទូតដែលយើងបានស្តាប់ អំពីរបស់ដែលព្រះសហាគមន៍បានចែកតួនាទីពីដើមរៀងមក នៅពេលនោះមានក្រុមគ្រិស្តទូតដែលទទួលខុសត្រូវការអធិដ្ឋានបម្រើព្រះបន្ទូល និងជួយអ្នកក្រីក្រ។ ប៉ុន្តែគេបានយល់ថា គេមានការងារច្រើនពេកដូច្នេះហើយគេបានជ្រើសរើស៧នាក់ ដើម្បីទទួលខុសត្រូវ ដូចជាជួយអ្នកក្រីក្រ ស្ត្រីមេម៉ាយ ក្មេងកំព្រា មនុស្សដែលគ្មានទីពឹង ដើម្បីបង្ហាញសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់។ ពីដើមរៀងមក ព្រះសហាគមន៍បានចែករបៀបធ្វើការយ៉ាងច្បាស់លាស់ មានក្រុមគ្រិស្តទូតដែលបម្រើតាមព្រះបន្ទូល (អប់រំណែនាំ ដើម្បីឲ្យគេស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់) ក្រុមគ្រិស្តទូតដែលយកចិត្តទុកដាក់អធិដ្ឋាន មានមួយចំនួនដែលទទួលខុសត្រូវក្នុងការចែករំលែកអំណរសប្បាយនិងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកហើយ យើងបានទទួលតួនាទីទាំងបីពេលយើងទទួលពិធីជ្រមុជទឹក យើងទៅជាបូជាចារ្យ (ជាអ្នកដែលបម្រើការអធិដ្ឋានថ្វាយបង្គំ អរព្រះគុណព្រះជាម្ចាស់) យើងទៅជាព្យាការី (ជាអ្នកដែលថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីណែនាំឲ្យមនុស្សឯទៀតៗអាចស្តាប់លឺនិងស្គាល់ព្រះជាម្ចាស់ថែមទៀត) យើងជាព្រះមហាក្សត្រ (ជាអ្នកបម្រើ)។ យើងរៀងៗខ្លួន យើងមានតួនាទីយកចិត្តទុកដាក់អធិដ្ឋានផង យកចិត្តទុកដាក់ប្រកាសដំណឹងល្អផង យកចិត្តទុកដាក់ដើម្បីបម្រើបងប្អូនឯទៀតៗ។

មេក្រុមកាយឫទ្ធិ បានទទួលបេសកកម្មមួយយ៉ាងពិសេស ដើម្បីបម្រើកូនក្មេងដែលជួបជុំគ្នាជារៀងរាល់សប្តាហ៍។ តួនាទីរបស់យើង ជាតួនាទីតាមរបៀបព្រះយេស៊ូតែម្តង ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំជាផ្លូវ ខ្ញុំជាសេចក្តីពិត ខ្ញុំជាជីវិត**"។ សម្រាប់មេក្រុមកាយឫទ្ធិ យើងអាចចូលក្នុងគម្រោងការរបស់ព្រះយេស៊ូដែរ ដើម្បីណែនាំកូនក្មេង ដើម្បីបំពេញតួនាទីរបស់យើង។ បងប្អូនជាគ្រិស្តបរិស័ទក៏ដូចគ្នាដែរ ឲ្យយើងចូលនៅក្នុងព្រះបន្ទូលរបស់

ព្រះយេស៊ូ។ ព្រះយេស៊ូជាផ្លូវ ណែនាំឲ្យយើងនឹកឃើញជីវិតរបស់យើងជាផ្លូវមួយ ដែលយើងដើរពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់អស់ផ្លូវ ប្រហែលជាថ្ងៃដែលយើងទទួលមរណៈភាព ប៉ុន្តែព្រះយេស៊ូជាផ្លូវ ណែនាំឲ្យយើងមានជីវិតអស់កាលជានិច្ច។ ផ្លូវរបស់យើងសព្វថ្ងៃ ពេលមានភ្លើងពណ៌ក្រហមយើងឈប់ ពេលមានភ្លើងពណ៌ខៀវយើងទៅមុខ ប្រសិនបើយើងមិនគោរពភ្លើងស្តុបយើង នឹងស្ទះដែលណែនាំមិនឲ្យយើងទៅមុខបានទេ។ ជីវិតរបស់យើងក៏ដូចគ្នាដែរ មានភ្លើងពណ៌ក្រហមណែនាំឲ្យយើងយល់ថានេះធ្វើមិនបាន មានភ្លើងពណ៌ខៀវដើម្បីណែនាំឲ្យយើងយល់ថាយើងអាចទៅមុខ ជាផ្លូវដែលត្រឹមត្រូវ។ យើងត្រូវយល់ថាផ្លូវនៃជីវិតរបស់យើងដែលមានព្រះយេស៊ូជាផ្លូវផ្ទាល់ខ្លួន ណែនាំឲ្យយើងត្រូវតែមានវិន័យ បើក្នុងជីវិតរបស់យើងពេលយើងដើរតាមផ្លូវនោះដោយគ្មានវិន័យ ជីវិតរបស់យើងមិនដឹងទៅណាច្បាស់លាស់ឡើយ។

សម្រាប់មេក្រុមកាយឫទ្ធិ យើងត្រូវធ្វើដូចម្តេចដើម្បីណែនាំឲ្យកូនក្មេងយល់អំពីវិន័យនៅក្នុងជីវិតផ្ទាល់ខ្លួន ដើម្បីធ្វើដំណើរទៅមុខលើផ្លូវនៃជីវិតនេះ។ វិន័យ យើងនឹកឃើញវិន័យរបស់ព្រះយេស៊ូមួយ ដើម្បីដឹកនាំរបៀបដែលយើងណែនាំកូនក្មេង គឺសូមស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។ ដូច្នេះពេលយើងជួបគ្នាជាមួយកូនក្មេង យើងមានវិន័យកាយឫទ្ធិ យើងមានរបៀបនិងបន្ថែមវិន័យដ៏សំខាន់នេះ សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។ ពេលយើងណែនាំឲ្យកូនក្មេងស្រឡាញ់គ្នាទៅវិញទៅមក ជីវិតទៅមុខ ពេលយើងជាមេក្រុមកាយឫទ្ធិយើងចេះស្រឡាញ់គ្នាទៅវិញទៅមកបរិយាកាសក្នុងកម្មវិធីកាយឫទ្ធិទៅមុខបាន ពេលក្នុងព្រះសហគមន៍យើងចេះស្រឡាញ់គ្នាទៅវិញទៅមកដើម្បីដឹកនាំជីវិតរបស់យើង ព្រះសហគមន៍របស់យើងរីកចម្រើន ហើយណែនាំឲ្យសង្គមរបស់យើងទៅជាសង្គមថ្មីដែរ។ ព្រះយេស៊ូជាផ្លូវ ព្រះអង្គមានភ្នែកមួយយ៉ាងពិសេសដើម្បីណែនាំឲ្យយើងដើរតាមផ្លូវនេះ គឺស្រឡាញ់គ្នាទៅវិញទៅមក ដោយយកចិត្តទុកដាក់បម្រើដូចព្រះយេស៊ូបានបម្រើយើង។

ទីពីរ ព្រះយេស៊ូជាសេចក្តីពិត យើងដឹងថាជីវិតរបស់យើងរកឃើញសេចក្តីពិតសំខាន់ណាស់។ សម្រាប់មេក្រុមកាយឫទ្ធិយើងធ្វើដូចម្តេច ដើម្បីណែនាំឲ្យកូនក្មេងដើរតាមផ្លូវនៃសេចក្តីពិត ដោយមានចិត្តស្មោះត្រង់ ដោយមានចិត្តអត់ធ្មត់ដល់បងប្អូនឯទៀតៗ។ នេះសំខាន់ណាស់ ដោយសារកម្មវិធីដែលយើងមានរាល់សប្តាហ៍គឺមានគោលដៅតែមួយ

ណែនាំឲ្យកូនក្មេងទៅជាពលរដ្ឋដ៏ល្អ ណែនាំឲ្យកូនក្មេងទៅជាមនុស្សដែលមានកម្លាំងកាយ កម្លាំងចិត្តនៅក្នុងជីវិត ដោយរស់នៅក្នុងភាពស្មោះត្រង់ចំពោះអ្នកដទៃ ចំពោះឪពុកម្តាយ ចំពោះសង្គម ដោយចេះរស់នៅក្នុងសេចក្តិពិតដ៏ពិតប្រាកដ។ យើងត្រូវការណែនាំក្មេងៗ យល់អំពីអ្វីដែលល្អនិងមិនល្អ។ បងប្អូនដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាសនៅសប្តាហ៍ខាងមុខ បងប្អូនបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលណែនាំបំភ្លឺយើង ឲ្យយើងទទួលខុសត្រូវ និងជាពិសេសឲ្យយើងចេះវិនិច្ឆ័យអ្វីដែលល្អនិងអ្វីដែលមិនល្អ។ នេះជារបៀបដែលព្រះយេស៊ូជាសេចក្តីសម្រាប់បភ្លឺយើង ហេតុនេះហើយយើងជាមេក្រុមកាយឫទ្ធិយើងមានធម្មវិន័យស្រឡាញ់គ្នាទៅវិញទៅមក និងណែនាំឲ្យកូនក្មេងដឹងថានេះល្អនេះមិនល្អ ដើម្បីរស់នៅក្នុងភាពស្មោះត្រង់ដោយកសាងជីវិតផ្ទាល់ខ្លួន ដើម្បីឲ្យក្មេងៗក្លាយជាមនុស្សដ៏ល្អនៅក្នុងសង្គមនាពេលអនាគត។

ទីបី ព្រះយេស៊ូជាជីវិត សកម្មភាពកាយឫទ្ធិត្រូវណែនាំឲ្យកូនក្មេងយល់អំពីតម្លៃនៃជីវិត ជាជីវិតដែលណែនាំឲ្យគេមានអំណរសប្បាយ ណែនាំឲ្យគេមានកម្លាំង។ ក្មេងៗពេលជួបជុំគ្នាគេចង់លេងចង់សប្បាយជាមួយគ្នា នេះជាសញ្ញានៃជីវិត។ តែឲ្យមានអំណរសប្បាយ ដែលណែនាំឲ្យយើងចេះចែករំលែកអំណោយទានយ៉ាងពិសេស ដែលយើងទទួលគឺជីវិតដ៏អស្ចារ្យដែលយើងបានទទួលពីឪពុកម្តាយ និងបានទទួលពីព្រះជាម្ចាស់។ យើងត្រូវណែនាំឲ្យកូនក្មេង ចេះស្រឡាញ់ ចេះគោរពជីវិត ទាំងធម្មជាតិ ទាំងសត្វ ទាំងមនុស្សឯទៀតៗ។ យើងនឹងចុះសួរសុខទុក្ខ ក្រុមគ្រួសារក្រីក្រ ចាស់ជរា និងអ្នកគ្មានទីពឹង ដើម្បីបង្ហាញថាជីវិតដែលយើងបានទទួលមានតម្លៃណាស់ នឹងយើងសប្បាយចិត្តចែករំលែកជីវិតនេះ អំណរសប្បាយនេះ សេចក្តីស្រឡាញ់នេះ ទៅបងប្អូនឯទៀត ជាពិសេសមនុស្សតូចតាចជាងគេ។ នៅថ្ងៃទី១ ខែមិថុនា ជាថ្ងៃបុណ្យសិទ្ធិកុមារ ហេតុនេះហើយតាមព្រះសហាគមន៍នីមួយៗឲ្យយើងមានសកម្មភាពមួយ ដើម្បីប្រមូលកូនក្មេងយ៉ាងច្រើនឲ្យគិតអំពីសិទ្ធិកុមារផ្ទាល់ខ្លួន ជាឱកាសមួយដើម្បីគិតអំពីជីវិតដែលយើងបានទទួល។ នៅក្នុងសិទ្ធិកុមារ មានមាត្រាជាច្រើនក្នុងនោះមាត្រា១ កូនក្មេងទាំងអស់មានសិទ្ធិទទួលជីវិតដ៏ថ្លៃថ្នូរ។ ព្រះយេស៊ូជាជីវិត កូនក្មេងមានជីវិតដ៏ពិសេសដែលគេបានទទួល នឹងណែនាំឲ្យកូនក្មេងអាចរកឃើញសេចក្តីសុខសាន្ត។ កូនក្មេងទាំងអស់មានសិទ្ធិមានសញ្ជាតិផ្ទាល់ខ្លួន មានអត្តសញ្ញាណផ្ទាល់ខ្លួន អាចទទួលបានការសិក្សា មានក្រុមគ្រួសារ រស់នៅជាមួយ

ឪពុកម្ដាយផ្ទាល់ខ្លួន អាចទទួលសេវាកម្មសុខភាព និងមានសេរីភាពក្នុងការដើរលេង។ មាត្រាដែលសំខាន់បំផុត គឺកូនក្មេងនីមួយៗមានជីវិតដ៏ថ្លៃថ្នូរ នឹងយើងត្រូវតែគោរពជីវិតនេះ។ ហេតុនេះហើយ មេក្រុមកាយឫទ្ធិយើងទទួលតួនាទីយ៉ាងសំខាន់ ដោយណែនាំឲ្យកូនក្មេងទទួលស្គាល់អំពីតម្លៃនៃជីវិត ហើយចែករំលែកជាមួយបងប្អូនឯទៀត។

សរុបសេចក្ដី យើងយល់ថាផ្លូវនៃជីវិតរបស់យើងវែងឆ្ងាយ ក្នុងផ្លូវនេះយើងមានមេក្រុមកាយឫទ្ធិ ធ្វើដូចម្ដេចដើម្បីណែនាំផ្លូវកូនក្មេងរបស់យើងឲ្យគេរកឃើញសេចក្ដីពិត និងណែនាំឲ្យគេទទួលជីវិតដ៏អស្ចារ្យដែលព្រះជាម្ចាស់ប្រទានឲ្យ ជាអំណោយទានមួយដើម្បីណែនាំឲ្យគេរស់នៅក្នុងសេចក្ដីសុខនិងសេចក្ដីសង្ឃឹមជានិច្ច។ ថ្ងៃនេះខ្ញុំ អធិដ្ឋានសម្រាប់មេក្រុមកាយឫទ្ធិទាំងអស់ សម្រាប់យើងទាំងអស់គ្នាដែលជាព្រះសហគមន៍ ដើម្បីឲ្យយើងរួមគ្នាណែនាំឲ្យកូនក្មេងមានអនាគតល្អ និងយកចិត្តទុកដាក់ស្រឡាញ់ យកចិត្តទុកដាក់បម្រើ ដើម្បីឲ្យសង្គមយើង គ្រួសារយើង ភូមិយើង ព្រះសហគមន៍របស់យើងទៅជាសញ្ញាសម្គាល់នៃព្រះយេស៊ូ គឺព្រះយេស៊ូដែលជាផ្លូវ ព្រះយេស៊ូដែលជាសេចក្ដីពិត និងព្រះយេស៊ូដែលជាជីវិត។ អាម៉ែន៕